- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានលុបឈ្មោះឯកឧត្តម **ឡៅ ស៊ុតគ្រា** ពីសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើអនុរដ្ឋលេខាធិការ ដោយមូលហេតុ មរណភាព។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្ត អោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព.រ.ល.០៦០៦.២៥៨

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦

លេខ : ៦៣៩ ច.ល

**ដើម្បីចម្លងចែកចាយ**

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊ុន ជិនភេន**

នស/រកត/០៦០៦/៧៤៤

# ព្រះរាជក្រឹត្យ
## ស្តីពី
## ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋាន វប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ហៅកាត់ "អ.ជ.ព.វ" ដែលជាគ្រឹះស្ថានសាធារណៈមួយប្រកបដោយបុគ្គលភាពគតិយុត្ត មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ។

គ្រឹះស្ថានសាធារណៈនេះ ស្ថិតនៅក្រោមអាណាព្យាបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌និងធម្មជាតិនៃប្រាសាទព្រះវិហារមានបេសកកម្មតិតគូរ ដឹកនាំ ការងាររៀបចំ និងអភិវឌ្ឍទេសចរណ៍ នៃតំបន់ចំនួន៤ (បួន) ដែលកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/ ១៨៣ ចុះថ្ងៃ ទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ។

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌និងធម្មជាតិនៃប្រាសាទព្រះវិហារព្រមជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើជាអាណាព្យាបាលរួមលើគ្រឹះស្ថាន និងនាយកដ្ឋានទាំងឡាយ ដែលមានភារកិច្ចទទួលខុសត្រូវជាក់ស្តែង ក្នុងការគ្រប់គ្រងរមណីយដ្ឋានប្រាសាទព្រះវិហារ ។

**មាត្រា ៣.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌និងធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ឱ្យមាន សៀវភៅបន្ទុកសម្រាប់អង្គការនានា ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងរមណីយដ្ឋាន និងការរៀបចំតំបន់ប្រាសាទព្រះវិហារ ។ ក្នុងន័យនេះ អាជ្ញាធរជាតិអាច :

- ចុះកិច្ចសន្យា អំពីកម្មវិធីប្រចាំឆ្នាំជាមួយអង្គការជាតិ និងអន្តរជាតិនានា
- ចុះកិច្ចសន្យា ជាមួយអាជ្ញាធរខេត្តដែលមានបំណងធ្វើការរៀបចំនគរូបនីយកម្ម ការអភិវឌ្ឍជនបទ និង ការផ្តល់សេវាផ្សេងៗជាយថាហេតុ
- សហការជាមួយគ្រប់វិទ្យាស្ថាន គ្រប់អង្គការផ្សេងៗ គ្រប់មូលនិធិ និងសហគមន៍ជាតិ និងអន្តរជាតិ ដែលដើរ តាមទិសដៅ ឆ្លើយតបនឹងសមត្ថកិច្ចអាជ្ញាធរជាតិ ។

**មាត្រា ៤.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌និងធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវធ្វើរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារ ការវិនិយោគ និងសេចក្តីអនុញ្ញាតផ្សេងៗ ដែលត្រូវបាន សម្រេចហើយ ជូនប្រមុខរាជរដ្ឋាភិបាល ។

## ជំពូកទី ២

## ក្រុមប្រឹក្សាភិបាល

**មាត្រា ៥.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌និងធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវបានដឹកនាំដោយ ក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| - ឥស្សរជនមួយរូប | ប្រធាន |
| - អភិបាលខេត្តព្រះវិហារ | សមាជិក |
| - តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ សមាជិក និងលេខាធិការ ។

សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាភិបាល មានភារកិច្ចដឹកនាំអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងមានសិទ្ធិអនុម័ត :

- ការតម្រង់ទិសរាល់សកម្មភាពរបស់អាជ្ញាធរជាតិ
- ការអនុញ្ញាតឱ្យប្រធានអាជ្ញាធរជាតិ ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាអន្តរជាតិទាំងឡាយ ស្របតាមនីតិវិធីជាធរមាន
- បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរជាតិ
- របាយការណ៍ប្រចាំឆ្នាំ ដែលប្រធានអាជ្ញាធរជាតិបានដាក់ជូន
- ចំនួនទឹកប្រាក់ ថ្លៃឈ្នួលផ្សេងៗ និងចំណូលគ្រប់បែបដែលអាជ្ញាធរប្រមូលបាន
- ចំនួនទឹកប្រាក់ និងលក្ខខណ្ឌនៃការខ្ចីបុល
- រាល់វិធានការ ដំណោះស្រាយបញ្ហាដែលប្រធានអាជ្ញាធរជាតិ ដាក់ជូនពិនិត្យ ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាភិបាល ត្រូវប្រជុំសាមញ្ញយ៉ាងតិច ២ (ពីរ) ដង ក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល និងអាចប្រជុំវិសាមញ្ញតាមការចាំបាច់ ក្នុងករណីមានការស្នើសុំពីប្រធាន ឬសមាជិកចំនួន ១/៤ ។

ប្រធានក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជន ឬអ្នកជំនាញ និងតំណាងក្រសួង ស្ថាប័ន ជាលក្ខណៈពិគ្រោះយោបល់មកចូលរួមបានក្នុងអង្គប្រជុំ បានតាមការចាំបាច់ដើម្បីផលប្រយោជន៍សម្រាប់អាជ្ញាធរជាតិនេះ ។

**មាត្រា ៨.-**

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាល មានរយៈពេល ៣ (បី) ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន។ ការបញ្ចប់អាណត្តិសមាជិកណាម្នាក់ ត្រូវធ្វើឡើងតាមសំណើរបស់ក្រសួងសាមី ។

**មាត្រា ៩.-**

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីអាណាព្យាបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

# ជំពូកទី ៣
# តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ១០.-**

ប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ គឺជាប្រធានអាជ្ញាធរជាតិនេះ ដែលមានសិទ្ធិអំណាចដូចមានចែងនៅក្នុងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៥១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងមានតួនាទី និងភារកិច្ចបន្ថែម ដូចតទៅ :

- ជាតំណាងឱ្យរាជរដ្ឋាភិបាលក្នុងគ្រប់កិច្ចប្រជុំ ពិធី និងការចរចាដែលពាក់ព័ន្ធនឹងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាទាំងឡាយដែលទាក់ទងនឹងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- ទទួលរ៉ាប់រងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងចាត់វិធានការគ្រប់គ្រងក្នុងដំណើរការរបស់អាជ្ញាធរជាតិ
- ជាអាណាប័កដើមខ្សែនៃអាជ្ញាធរជាតិ ដែលមានតួនាទីត្រួតពិនិត្យចំណូល និងបញ្ជាចំណាយផ្សេងៗ
- តែងតាំង និងដំឡើងឋានន្តរស័ក្តិភ្នាក់ងារ និងបុគ្គលិក បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល
- ដឹកនាំ គ្រប់គ្រងជាប្រចាំលើសកម្មភាពការងាររបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិនេះ ។

**មាត្រា ១១.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានអគ្គនាយកដ្ឋានមួយជាសេនាធិការ ដែលត្រូវបានដឹកនាំ គ្រប់គ្រង ដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់ ។ អគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិនេះ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១២.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ទទួលបន្ទុកការពារ អភិរក្ស និងគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវធ្វើសកម្មភាពឱ្យស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា៥ នៃព្រះរាជក្រមលេខ នស/រកម/ ០១៩៦/26 ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ព្រមទាំងកាតព្វកិច្ចអន្តរជាតិ ។

អាជ្ញាធរជាតិនេះ មានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់ សម្រាប់ការស្ថាបនាទាំងឡាយក្នុងរង្វង់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ។ ការអនុញ្ញាតសាងសង់ដែលចេញដោយអាជ្ញាធរផ្សេងក្រៅពីអាជ្ញាធរជាតិនេះ ទាក់ទងទៅនឹងសំណង់នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារត្រូវចាត់ទុកជាមោឃៈ ។ សំណង់កសាងរួចហើយក្នុងតំបន់ការពារដែលគ្មានច្បាប់អនុញ្ញាត ត្រូវរុះរើចេញដោយម្ចាស់សំណង់ដោយគ្មានលក្ខខណ្ឌ ក្នុងរយៈពេល ៤៥ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃជូនដំណឹង ។

អាជ្ញាធរជាតិនេះត្រូវទទួលភារកិច្ចផ្ទាល់មុខ ជាអ្នកចាត់ចែងគ្រប់ការងារទាំងអស់ក្នុងបរិវេណរមណីយដ្ឋាននេះ លើកលែងតែកិច្ចការណាដែលទាក់ទងនឹងបញ្ហាព្រំដែន ។

## ជំពូកទី ៤
## ទិសមិតភាព

**មាត្រា ១៣.-**

ប្រធាន សមាជិកទាំងអស់ និងនាយកហិរញ្ញកិច្ច និងគណនេយ្យ នៃក្រុមប្រឹក្សាភិបាលរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ពុំអាចទទួលផលប្រយោជន៍អ្វី ដោយផ្ទាល់ ឬតាមរយៈស្វាមី ឬភរិយា ឬកូនរបស់ខ្លួននៅក្នុងសហគ្រាសឯកជនណាមួយ ដែលធ្វើអាជីវកម្មក្រោមសមត្ថកិច្ចអាជ្ញាធរជាតិនេះឡើយ ។

ក្នុងករណីមិនគោរពកាតព្វកិច្ចនេះ ក្រុមប្រឹក្សាភិបាលត្រូវធ្វើកំណត់ហេតុស្តីពីវិសមិតភាពការងាររបស់សាមីជន ហើយប្រកាសឱ្យលាលែងពីមុខតំណែងតែម្តង ។

## ជំពូកទី ៥
## ប្រភពធនធាន

**មាត្រា ១៤.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានធនធានជា :

- វិភាគទានពីរដ្ឋ និងពីឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង
- អំណោយ និងវិភាគទានអន្តរជាតិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិនេះ
- ចំណូលបានមកពីសកម្មភាពផ្ទាល់របស់អាជ្ញាធរជាតិ ដូចជាបំណុល ថ្លៃឈ្នួល បានមកពីការចេញច្បាប់កាន់កាប់ផ្សេងៗ
- ប្រាក់កម្រៃបានមកពីប្រភពសេវាកម្មផ្សេងៗ ផ្តល់មកពីអង្គការសាធារណៈ ឬឯកជន
- កម្ចីដែលធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ
- ចលនវត្ថុ និងអចលនវត្ថុ ដែលសប្បុរសជន អង្គការជាតិ និងអន្តរជាតិប្រគល់ឱ្យ ។

**មាត្រា ១៥.-**

គម្រោងចំណូល និងចំណាយសម្រាប់ឆ្នាំបន្ទាប់ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយ៉ាងយូរបំផុតនៅថ្ងៃទី ០១ ខែតុលា ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.–**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៩៧.០៦០៦.២៥៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ : ២៤០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

នស/រកត/០៦០៦/២៥០

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង :

១- ឯកឧត្តម ជូ គឹមឡេង ជាសមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម វង្ស ប៊ុនឥន្ទ្រាវុធ ជាជំនួយការស្រាវជ្រាវ របស់ឯកឧត្តម វង់ សណ្ដាប់ សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** ត្រូវបានតម្លើងឋានៈ :

១- ឯកឧត្តម ហ៊ាន សាហ៊ីប អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ឈន សុភាព ជំនួយការស្រាវជ្រាវអមប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នស.រកត.០៦០៦.២៦១*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦*

លេខ :២៤២ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ឈុន ចិនកេង**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៦/២៥១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០២ ០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី ៤ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីសម្រេចលេខ ០៣៥ រ.ស ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.** ត្រូវបានតែងតាំង :

| | |
|---|---|
| ១- លោកជំទាវ **ស៊ុខ ស៊ីយុត** | ជាអគ្គនាយក នៃអគ្គនាយកដ្ឋានសេវា និងបច្ចេកទេស នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ២- ឯកឧត្តម **ឡាច ឈឿង** | ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៣- ឯកឧត្តម **មិត្ត ភារ៉េង** | ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៤- ឯកឧត្តម **ស្រី សារ៉េត** | ជាប្រធានមជ្ឈមណ្ឌលច្បាប់ មានឋានៈស្មើអគ្គនាយក នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា |

**មាត្រា ២.** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបាន សម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០៦០៦.២៦២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៦*

លេខ : ២៤៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ២០០៦
**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**
**ឃុន ជិនកេង**

នស/រកត/០៦០៦/២៥២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម មីសែល ត្រានណេ ពីអនុប្រធាននៃគណៈកម្មការជាតិយូណេស្កូកម្ពុជា។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧ល.០៦០៦.២៦៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០០៦*

លេខ : ២៤៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៦/២៥៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដាក់សាស្ត្រាចារ្យមហាបរិញ្ញា **ម៉ី មិតជីនីស** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រ បាណកសាស្ត្រ ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ ឱ្យចូលនិវត្តន៍ ក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល-០៦០៦-៦៦៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០០៦

លេខៈ ៤៤៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៦/២៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី ៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំង :

១-ឯកឧត្តម **មុំ ខេង** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភាទទួលបន្ទុកជានាយកខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

២-ឯកឧត្តម **ស៊ាម គុសល** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភាទទួលបន្ទុកជានាយករងខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

៣-ឯកឧត្តម **ចាន់ ធឿន** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភាទទួលបន្ទុកជានាយករងខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២** : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

ពរស-០៦០៦-២៦៥

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ,ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០០៦

លេខៈ ២៤៣ ជ.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេង**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានចំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន១៤គ្រឿង ប្រគេននិង ជូនសប្បុរសជនចំនួន១៤រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកា ចូលរួមជួយកសាងសមិទ្ធផលនានា រួមមានមណ្ឌល សុខភាព អគារសិក្សា កុដិ ស្ពាន ធ្វើរបងព័ទ្ធជុំវិញមណ្ឌលសុខភាព និងសមិទ្ធផលជាច្រើន ទៀត នៅក្នុងពុទ្ធសីមា *វត្តព្រហ្មមានជ័យ សុវណ្ណរាម* ហៅ *វត្តវាំងខ្ពង់* ភូមិអន្លង់ស្វាយ ឃុំនិមិត្ត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ខាំ ឈយ ផនឆៃ** | ចៅអធិការ | បច្ច័យចំនួន ១៦.០២៣ ដុល្លារ |
| ២-ព្រះតេជគុណ | **ថូ ស៊ីម៉ាច់** | | បច្ច័យចំនួន ១៣.០០០ ដុល្លារ |
| ៣-លោក | **តាន់ ស្វាង** | | ថវិកា ចំនួន ១៣.០០០ ដុល្លារ |
| ៤-លោក | **ឃួន ខាំ សេង** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១២.០០០ ដុល្លារ |
| ៥-លោក | **ឈយ មីថង** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ១២.០០០ ដុល្លារ |
| ៦-អ្នកស្រី | **ឈាង ស៊ុយាឡាត** | នៅប្រទេសបារាំង | ថវិកា ចំនួន ១២.០០០ ដុល្លារ |
| ៧-អ្នកស្រី | **ទ្រី ជូ** | នៅបទេសបារាំង | ថវិកា ចំនួន ១១.៥០០ ដុល្លារ |
| ៨-លោក | **ខាំផាន់ ម៉ាលីថៃ** | នៅប្រទេសកាណាដា | ថវិកា ចំនួន ១១.៥០០ ដុល្លារ |
| ៩-លោក | **ភ្នាំ នីមអ៊ា អ្នកស្រី កែង** | | ថវិកា ចំនួន ១១.៥០០ ដុល្លារ |
| ១០-លោក | **ឡេ ម៉េង និងអ្នកស្រី ឆា** | | ថវិកា ចំនួន ១១.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| -លោក | **ចិល សេដ្ឋា** | | ថវិកា ចំនួន ៥.៣០០ ដុល្លារ |

**គ-មេដាយសេរីវឌ្ឍនាបនាជាតិ :**

| | | |
|---|---|---|
| ១-លោក | **ចេង ផន** | ថវិកា ចំនួន ៤.០០០ ដុល្លារ |
| ២-លោក | **ផេង ថង** | ថវិកា ចំនួន ៤.០០០ ដុល្លារ |
| ៣-លោក | **ផេង ឌីមហ៊ា** | ថវិកា ចំនួន ៤.០០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន១៦រូប ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគបច្ច័យ និងថវិកា ចូលរួមជួយកសាងព្រះវិហារ សាលាធម្មសភា និងឧបដ្ឋានសាលា នៅក្នុងពុទ្ធសីមាវត្ត អង្គពពាយមានជ័យ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **គិន ចន្ថា** ព្រះគ្រូសូត្រស្តាំ វត្តអង្គពពាយមានជ័យ បច្ច័យចំនួន ១១.៥៨០ ដុល្លារ
២-ឧត្តមសេនីយ៍ត្រី **សិន ចំនួ** ថវិកាចំនួន ១០.១០០ ដុល្លារ
៣-លោក **ទៀន សាម៉ន** ថវិកាចំនួន ១០.៤០០ ដុល្លារ
៤-ឧបាសិកា **អឿ ជាឈៀង** សប្បុរសជននៅភ្នំពេញ ថវិកាចំនួន ១០.៩៤០ ដុល្លារ
៥-ឯកឧត្តម **ឃុន កុសល្ល** ទីប្រឹក្សាអមក្រសួងធម្មការនិងសាសនា ថវិកាចំនួន ១០.៥០០ ដុល្លារ
៦-លោកស្រី **ឃុន អេឡេណា** សប្បុរសជននៅភ្នំពេញ ថវិកា ចំនួន ១០.១០០ ដុល្លារ
៧-លោក **ប្រាក់ ស៊ីដេត** សប្បុរសជន ថវិកា ចំនួន ១១.៥០០ ដុល្លារ
៨-វរសេនីយ៍ឯក **ម៉េង រ៉ា** ថវិកា ចំនួន ១០.២០០ ដុល្លារ

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ព្រាប ម៉ុម** ចៅអធិការវត្តអង្គពពាយមានជ័យ បច្ច័យចំនួន ៩.២០០ ដុល្លារ
២-លោកជំទាវ **ហូ ឈុន** ថវិកាចំនួន ៦.៥០០ ដុល្លារ
៣-លោក **ចំនួ គីមខុង** ថវិកាចំនួន ៦.២០០ ដុល្លារ
៤-ឧបាសិកា **ថៃ ឈៀង** ថវិកាចំនួន ៥.៧០០ ដុល្លារ

| | | | |
|---|---|---|---|
| ៥-ព្រះតេជគុណ | **យូខ សាន់** | ចៅអធិការវត្តព្រៃពួច | បច្ច័យចំនួន ៥.២០០ ដុល្លារ |
| ៦-ឧបាសិកា | **សៅ ឈីស** | | ថវិកាចំនួន ៥.៣០០ ដុល្លារ |
| ៧-លោក | **គង់ នៅ** | | ថវិកាចំនួន ៥.២៥០ ដុល្លារ |

**គ-មេដាយសេរីវឌ្ឍស្ថាបនាជាតិ :**

| | | |
|---|---|---|
| -លោកឌុំ | **គង់ ឈន់** | ថវិកា ចំនួន ៣.២០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៨៨....អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន០៦គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន០៦រូប ដែលបានជួយកសាងកុដិ និងសមិទ្ធផលនានា ជាច្រើនទៀត នៅក្នុងវត្តបុទុមគង្គា ហៅ បាក់ខែង សង្កាត់ព្រែកលាប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ចឺន ម៉ិនខេម** | ព្រះចៅអធិការវត្ត | បច្ច័យចំនួន ១២.៥៦៨ ដុល្លារ |
| ២-លោក | **ឈន់ ចៅលីម** | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១២.២០០ ដុល្លារ |
| ៣-លោក | **ហ៊ី ឌួចឆេង** | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១១.៣៣០ ដុល្លារ |
| ៤-អ្នកស្រី | **សេង ឌួចណាង** | សប្បុរសជន | ថវិកាចំនួន ១១.១១៥ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **សុក សារឿន** | សប្បុរសជន | ថវិកាចំនួន ៨.២០៥ ដុល្លារ |
| ២-លោក | **កែវ ខាន់** | ប្រធានគណៈកម្មការសាងសង់វត្ត | ថវិកាចំនួន ៦.១៣៥ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញៈថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៦៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃមន្ទីរធម្មការ និងសាសនា ខេត្តកោះកុង ចំនួន០៨រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ លើវិស័យព្រះពុទ្ធសាសនា និងសង្គមជាតិ ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

-លោក **ជួង សារឿន** ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តកោះកុង

**ខ.មេដាយប្រាក់ការងារ :**

១-លោក **ឯក នុង** អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្តកោះកុង

២-លោក **សំ ឡឿន** អនុប្រធានការិយាល័យរដ្ឋបាល

**គ.មេដាយសំរឹទ្ធការងារ :**

១-លោក **ឆេង ស៊ីផាន់** ប្រធានការិយាល័យសាសនសិក្សាធិការ

២-លោក **ចន្ទ្រា ឧត្តរាស់** ប្រធានការិយាល័យធម្មការ

៣-លោក **នុន ឌី** ប្រធានការិយាល័យធម្មការ និង សាសនា ស្រុកកំពង់សីលា

៤-លោក **អេង វ៉ាន់** ប្រធានការិយាល័យធម្មការ និង សាសនា ស្រុកស្មាច់មានជ័យ

៥-លោក **ពេជ សាវ៉ាត់** ប្រធានការិយាល័យធម្មការ និង សាសនា ស្រុកគីរីសាគរ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៥០....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៧រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានាជាច្រើន លើវិស័យព្រះពុទ្ធសាសនា នៅក្នុងពុទ្ធសីមា *វត្តប្រាសាទវង្គី* (ហៅ វត្តត្បូង) ឃុំព្រៃកដិបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ ម៉ូ **ស៊ីម៉ាប់** ទីប្រឹក្សាសម្តេចព្រះសង្ឃរាជ ទេព វង្ស និងជាប្រធានការកសង្ឃវត្តមហាមន្ត្រី បរិច្ចាគបច្ច័យ ចំនួន ១២.៥២០ ដុល្លារ ។

២-ព្រះគ្រូចន្ទព្តោ **ឃួន ចន** ចៅអធិការ វត្តប្រាសាទវង្គី បច្ច័យចំនួន ១០.៥០០ ដុល្លារ ។

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោកស្រី **ជ័យ សាធ៊ាន** | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ៦.៣៨០ ដុល្លារ |
| ២-លោក **តូច ជាង** និង ភរិយា | នៅសហរដ្ឋអាមេរិក | ថវិកាចំនួន | ៦.១៨៥ ដុល្លារ |
| ៣-ឧបាសក **សុខ ម៉ៃអ៊ាង** | | ថវិកាចំនួន | ៥.៤៨៤ ដុល្លារ |
| ៤-ឧបាសក **ស៊ាង ស្រេង** | | ថវិកាចំនួន | ៥.១៧៥ ដុល្លារ |
| ៥-លោក **អ៊ុត ឃាត់** | | ថវិកាចំនួន | ៥.៦៨៧ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីកីឡា ០២រូប ដែលមានស្នាដៃល្អប្រសើរ ក្នុងការលើកកំពស់កិត្យានុភាពជាតិក្នុងវិស័យកីឡាកន្លងមក ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **មាស សារិន** អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា

២-ឯកឧត្តម **ព្រាប សិទ្ធត្រា** អតីតប្រធានខេមរៈសហព័ន្ធកីឡាតេក្វាន់ដូ អណត្តិ ១៩៩៩-២០០៣

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៦

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

16

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន ០៤រូប ដែលបានបរិច្ចាគធនធានជួយសាងសង់អគារសិក្សា ០១ខ្នង កុដិ ០១ខ្នង ខ្លោងទ្វារ និងរបង ប្រវែង ៧២៩ ម៉ែត្រ នៅវត្តឱង្គារ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានព្រះនាម និងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| -លោកយាយ **ខ្ញឹម ផុល** | នៅសហរដ្ឋអាមេរិក | ថវិកា ចំនួន ២១.៦០០ ដុល្លារ |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| -ព្រះតេជគុណ **អួន អឿត** | គ្រូសូត្រស្តាំវត្តឱង្គារ | បច្ច័យ ចំនួន ៦.៥០០ ដុល្លារ |

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-លោក **នេត្រ ម៉ៃគឿន** | នៅរាជធានីភ្នំពេញ | ថវិកា ចំនួន ៣.២០០ ដុល្លារ |
| ២-លោក **យឹម យ៉ិន** | នៅឃុំទួលព្រេជ | ថវិកា ចំនួន ៤.៣០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០[illegible] ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៩៣...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៤រូប នៃអង្គការសប្បុរសធម៌ ជប៉ុន *ហ្គោតូ ហ្វូមីអូ* ដែលបានឧបត្ថម្ភថវិកា ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៣បន្ទប់ បំពាក់ដោយសម្ភារៈគ្រប់ប្រភេទ និងបង្គន់អនាម័យ នៅសាលាបឋមសិក្សាព្រៃទទឹង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់សរុបចំនួន ២១.៥១៤.៤៥ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

| | |
|---|---|
| ១-លោកឪពុក **GOTO Fumio** | ថវិកា ចំនួន ៥.៣៦៤.៧៦ USD |
| ២-លោក **Amatak** | ថវិកា ចំនួន ៥.៣៨៣.១៩ USD |
| ៣-លោក **Hatanaka** | ថវិកា ចំនួន ៥.៣៧៣.១៩ USD |
| ៤-លោក **Meas Bunra** | ថវិកា ចំនួន ៥.៣៩៣.៣១ USD |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣២៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានជួយកសាង នូវសមិទ្ធផលសាធារណៈផ្សេងៗ ដូចជា ព្រះវិហារ បណ្ណាល័យ ប្រឡាយទឹក ផ្លូវលំ ការងារសង្គមកិច្ច ។ល។ នៅឃុំ គោកធ្លក និង ឃុំពន្លៃ ស្រុកអង្គរបូរី ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោកជំទាវ | យូ អយ | នៅក្រុងភ្នំពេញ | ថវិកាចំនួន ២៦.០០០ ដុល្លារ |
| ២-ឧកញ៉ា | ឡុង ហ៊ីង | នៅក្រុងភ្នំពេញ | ថវិកា ចំនួន ១០.៩០០ ដុល្លារ |
| ៣-លោក | យូ ឆាសិទ្ធ | នៅក្រុងភ្នំពេញ | ថវិកា ចំនួន ៣៨.០០០ ដុល្លារ |
| ៤-លោក | ឡុង ឈាង | នៅក្រុងភ្នំពេញ | ថវិកា ចំនួន ១១.៩០០ ដុល្លារ |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | គីម សារិទ្ធ | នៅខេត្តតាកែវ | ថវិកា ចំនួន ៥.៣០០ ដុល្លារ |
| ២-លោកតា | អ៊ុក អួន | នៅក្រុងភ្នំពេញ | ថវិកា ចំនួន ៥.៧០០ ដុល្លារ |

**គ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោកតា | អ៊ុក សយ | នៅខេត្តតាកែវ | ថវិកា ចំនួន ១.១៨០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ... ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣១៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក WATANABE MIKI ប្រធានអង្គការ SCHOOL AID JAPAN ដែលបានឧបត្ថម្ភថវិកា ចំនួន ១៩.៣៩៤ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៣បន្ទប់ នៅសាលាបឋមសិក្សា ក្តីឈ្លូល ភូមិក្តីឈ្លូល ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៩៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីឃុំដីឥដ្ឋ និងគណៈកម្មការវត្តដីឥដ្ឋ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ចំនួន០៣រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋាន ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

-លោក **ស៊ុត តូ** មេឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល

**ខ.មេដាយប្រាក់ការងារ :**

១-លោកតា **អៀម ម៉ាន** អាចារ្យវត្តដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល

២-លោក **យី រ៉ាន់** ប្រធានគណៈកម្មការវត្តដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: [illegible] អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

